**សេចក្តីប្រកាសសារព័ត៌មានរួម**

សម្រាប់ចេញផ្សាយនៅថ្ងៃអង្គារ៍ ទី២១ ខែកញ្ញា ឆ្នាំ២០២១ ម៉ោង៧ព្រឹក ម៉ោងនៅកម្ពុជា

# កំណត់ត្រាលើកដំបូងបង្អស់ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនៃហ្វូងកូនសត្វក្រពើភ្នំដ៏កម្របំផុតនៅក្នុងតំបន់ទីជម្រកស្រែពក ផ្តល់ក្តីសង្ឃឹមដល់ការអភិរក្សជាសាកល

**ដែនជម្រកសត្វព្រៃស្រែពក ខេត្តមណ្ឌលគិរី ប្រទេសកម្ពុជា៖** អមជាមួយនឹងក្តីរំភើបរីករាយឥតឧបមា ក្រុមអ្នកវិទ្យាសាស្ត្រផ្នែកស្រាវជ្រាវសត្វព្រៃនៃក្រសួងបរិស្ថាន និងអង្គការWWF បានផ្តល់របាយការណ៍កាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១នេះ ដោយបញ្ជាក់ថាពួកគេបានប្រទះឃើញហ្វូងកូនសត្វក្រពើភ្នំ(*Crocodylus siamensis*) ដែលជាប្រភេទសត្វកំពុងរងគ្រោះថ្នាក់ជិតផុតពូជបំផុត សរុបចំនួន ៨ក្បាល ខណៈពេលដែលពួកគេបានចុះតាមដាន និងស្រាវជ្រាវសត្វនេះ នៅក្នុងដែនជម្រកធម្មជាតិនៃតំបន់ស្រែពកក្នុងអំឡុងពេលនៃរដូវពងនិងញាស់កូនរបស់វា។ សកម្មភាពតាមដាន សិក្សានេះ ជាផ្នែកមួយនៃកម្មវិធីស្រាវជ្រាវអំពីសត្វក្រពើភ្នំនៃគម្រោងកាំប៉ាស(CAMPAS) ដឹកនាំដោយក្រសួងបរិស្ថាន និងគាំទ្រផ្នែកហិរញ្ញវត្ថុដោយ GEF-5/UNEP ហើយមានការរួមថវិការបន្ថែមពី អង្គការWWF ប៊ែលហ្ស៊ិក។

ស្ថិតក្រោមលក្ខខណ្ឌអាកាសធាតុដ៏លំបាក ហើយជួបជាមួយនឹងភាពអត់ធ្មត់ខ្ពស់ គំហើញនៃសត្វដ៏កម្រមួយប្រភេទនេះត្រូវបានកត់ត្រាទុកនៅទីតាំងស្រាវជ្រាវមួយដែលអ្នកវិទ្យាសាស្ត្រធ្លាប់បានប្រមូលលាមក និងដានជើងរបស់វាកាលពីអំឡុងរដូវប្រាំងនៃឆ្នាំដដែលនេះ។ ហ្វូងកូនសត្វក្រពើភ្នំទាំងនេះ បច្ចុប្បន្នកំពុងរស់នៅដោយសុវត្ថិភាពនៅក្នុងទីជម្រកធម្មជាតិរបស់ពួកវាក្រោមការការពារយ៉ាងតឹងរ៉ឹងដោយមន្ត្រីឧទ្យានុរក្សនៃដែនជម្រកសត្វព្រៃស្រែពកនៃខេត្តមណ្ឌលគិរី។

**លោក ម៉ិន សុធា** សមាជិកម្នាក់នៃក្រុមអ្នកស្រាវជ្រាវបានរៀបរាប់ថា៖ «ក្នុងរដូវកូនក្រពើញាស់នេះ ក្រុមអ្នកស្រាវជ្រាវយើងបានធ្វើការតាមដានជាប្រចាំ ហើយសម្រាប់ការចុះតាមដានមួយជើងនេះ ពួកយើងបានចំណាយអស់រយៈពេល ៤យប់ ដើម្បីអង្កេតមើលស្ថានភាពរបស់សត្វក្រពើភ្នំនៅតាមទីតាំងផ្សេងៗរបស់វា គឺចាប់តាំងពីម៉ោង ៧:០០យប់ រហូតដល់រំលងអធ្រាត្រប្រហែលទល់ ម៉ោង២:០០ព្រឹក»។ លោកបានបន្តទាំងមានស្នាមញញឹមផងថា៖ «ភាពរំភើបត្រេកអរជាខ្លាំងក៏បានមកដល់ក្រោយពេលដែលសមាជិកក្រុមការងារយើងម្នាក់បានប្រទះឃើញចំណាំងពន្លឺភ្នែករបស់កូនសត្វក្រពើដែលទើបនឹងញាស់»។

គំហើញនៃហ្វូងកូនសត្វក្រពើភ្នំនាពេលនេះ គឺជាភស្តុតាងបញ្ជាក់ដោយរូបភាពដំបូងបង្អស់នៃការរស់រានបន្តពូជរបស់សត្វនេះក្រោយការខិតខំស្រាវជ្រាវអស់រយៈពេលជាងមួយទសវត្សរ៍នៅក្នុងដែនជម្រកសត្វព្រៃស្រែពក ដែលជាតំបន់ការពារធម្មជាតិមួយនៃតំបន់ព្រៃទេសភាពភាគខាងកើត ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាននិងគាំទ្រដោយអង្គការWWF ។

**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានមានប្រសាសន៍ថា៖ "នេះគឺជាដំណឹងដ៏ល្អមួយដែលយើងត្រូវសាទរ និងជាផ្លែផ្កាមួយនៃកិច្ចសហប្រតិបត្តិអភិរក្សរវាងក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា អង្គការWWF និងអង្គការដៃគូ ជាពិសេសសមាជិកទាំងអស់នៃក្រុមការងារស្រាវជ្រាវវិទ្យាស្រាស្ត្រនៃក្រសួងបរិស្ថាន និងអង្គការWWF ដែលបានខិតខំប្រឹងប្រែង

សិក្សានិងស្រាវជ្រាវរហូតទទួលបាននូវលទ្ធផលដោយបានកត់ត្រាបញ្ជាក់ជាផ្លូវការលើកដំបូងបង្អស់នៃហ្វូងកំពុងបន្តពូជនៃសត្វក្រពើភ្នំដ៏កម្របំផុតនេះនៅតំបន់ស្រែពក»។ **ឯកឧត្តមរដ្ឋមន្ត្រី**បានបន្តទៀតថា៖ «គំហើញនៃហ្វូងកូនសត្វក្រពើភ្នំនេះបានបង្ហាញឲ្យឃើញពីសារៈសំខាន់នៃដែនជម្រកសត្វព្រៃស្រែពក ជាតំបន់ជីវៈចម្រុះសកលមួយដែលមានសក្តានុពលខ្ពស់សម្រាប់ការស្តារធនធានជីវៈចម្រុះ និងចំនួនសត្វព្រៃសំខាន់ៗមានតម្លៃជាសកលឡើងវិញ»។

**ឯកឧត្តមរដ្ឋមន្ត្រី**ក៏បានមានប្រសាសន៍បន្ថែមទៀតថា៖ «ដំណឹងដ៏រំភើបនេះក៏បានឆ្លុះបញ្ចាំងផងដែរពីសារៈសំខាន់នៃព្រះរាជាណាចក្រកម្ពុជាសម្រាប់ការអភិរក្សសត្វក្រពើភ្នំដ៏កម្រ និងសត្វព្រៃសំខាន់ៗដទៃជាច្រើនប្រភេទទៀត។ ប្រទេសកម្ពុជាគឺជាប្រទេសដែលមានធនធានធម្មជាតិដ៏វិសេសវិសាលគ្មានពីរ ដែលនេះគឺជាមោទនភាពជាតិសម្រាប់ប្រជាជនកម្ពុជាទាំងអស់។ ដោយសារកម្ពុជាមានសន្តិភាពពេញលេញ យើងទាំងអស់គ្នា ទាំងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនៃគ្រប់វិស័យ មានលទ្ធភាពក្នុងការផ្តោតការយកចិត្តទុកដាក់ និងរិះរកគ្រប់មធ្យោបាយ និងដំណោះស្រាយនានាក្នុងកិច្ចគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ សំដៅឈានឆ្ពោះទៅស្តារធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីដែលកម្ពុជាមាន ឲ្យសំបូរ និងប្រសើរឡើងវិញ»។

ផ្អែកតាម**កញ្ញា Milou Groenenberg** ជាប្រធានផ្នែកស្រាវជ្រាវនិងតាមដានជីវៈចម្រុះនៃអង្គការWWF របកគំហើញនាពេលនេះត្រូវបានអ្នកវិទ្យាសាស្ត្រចាត់ទុកថាជាការវិវត្តន៍ដ៏វិជ្ជមានមួយ នៃការសិក្សាស្តីពីសត្វក្រពើភ្នំនៅក្នុងតំបន់នៃដែនជម្រកសត្វព្រៃស្រែពក ដោយហេតុថាវត្តមានរបស់សត្វនេះមិនត្រូវបានគេបញ្ជាក់ជាផ្លូវការទេ បើផ្អែកតាមរបាយការណ៍ស្រាវជ្រាវនានាដែលគេធ្លាប់ទទួលបានកាលពីរយៈពេលជាច្រើនឆ្នាំកន្លងមក ហើយរីឯការកត់ត្រាវត្តមានរបស់វាតាមរយៈរូបភាពក៏គ្មានដែរក្នុងទសវត្សរ៍ចុងក្រោយនេះ។

កញ្ញា **Milou** បាននិយាយថា៖ «កាលពីមុនអ្នកវិទ្យាសាស្ត្រនៅមិនទាន់អាចបញ្ជាក់ច្បាស់បានទេថាសត្វក្រពើភ្នំដែលរស់នៅក្នុងទីជម្រកស្រែពកនេះអាចមានគូបង្កាត់ពូជបាន ហើយក៏គេកាន់តែមិនអាចបញ្ជាក់បានទៀតថា តើសត្វនេះបានធ្វើសំបុកនៅទីណាមួយក្នុងតំបន់នេះ ហើយមានញាស់កូនដែរឬអត់ នោះឡើយ»។

អ្នកវិទ្យាសាស្ត្ររូបនេះបានបន្ថែមថា៖ «គំហើញនៃហ្វូងកូនសត្វក្រពើភ្នំនៅតំបន់ស្រែពកពេលនេះពិតជាផ្តល់នូវក្តីសង្ឃឹមសម្រាប់ការអភិរក្ស និងការពារការរស់រានរបស់សត្វនេះនៅក្នុងទីជម្រកធម្មជាតិរបស់វា ដែលវាមានសារៈសំខាន់ណាស់សម្រាប់កម្ពុជា និងពិភពលោកទាំងមូល»។

សត្វក្រពើភ្នំ ធ្លាប់មានរស់នៅពាសពេញតំបន់អាស៊ីអាគ្នេយ៍ ប៉ុន្តែចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៩០មក វត្តមានរបស់សត្វប្រភេទជិតផុតពូជបំផុតមួយនេះ ត្រូវបាត់បង់គួរឲ្យបារម្ភពីដែនជម្រកធម្មជាតិរបស់ពួកវា។ ប្រទេសកម្ពុជា គឺជាទីជម្រកសំខាន់ជាសកលមួយសម្រាប់ការរស់រាននៃសត្វក្រពើភ្នំ ដែលត្រូវបានគេប៉ាន់ប្រមាណថាមានចំនួនសរុប ចន្លោះពី ២០០ ទៅ ៤០០ក្បាល កំពុងរស់នៅក្នុងទីជម្រកធម្មជាតិនានាក្នុងប្រទេស។ នៅលើពិភពលោក ចំនួនសត្វក្រពើភ្នំដែលស្ថិតក្នុងវ័យអាចបន្តពូជបាន មានប្រមាណមិនលើសពី ១.០០០ (១ពាន់) ក្បាលឡើយ។

កត្តាគំរាមកំហែងចំពោះការរស់រានរបស់សត្វក្រពើភ្នំមានដូចជា៖ ការរេចរិលនិងការបាត់បង់ទីជម្រក ការបរបាញ់ខុសច្បាប់ដែលបណ្តាលមកពីតម្រូវការនៃការជួញដូរសត្វព្រៃខុសច្បាប់ ការចាប់ដោយខុសច្បាប់ដើម្បីផ្គត់ផ្គង់កសិដ្ឋានចិញ្ចឹមក្រពើ ការចាប់យកទៅបង្កាត់ពូជជាមួយពូជក្រពើផ្សេង ទំនប់វារីអគ្គិសនី និងការនេសាទដោយប្រើឧបករណ៍ខុសច្បាប់ជាដើម។

ការរស់រានរបស់កូនក្រពើភ្នំដែលទើបត្រូវបានគេស្រាវជ្រាវឃើញពេលនេះ ព្រមទាំងការការពារទីជម្រករបស់ពួកវាដោយសុវត្ថិភាពល្អ ត្រូវបានស្ថិតក្រោមការធានា និងឃ្លាំមើលយ៉ាងតឹងរ៉ឹងដោយមន្ត្រីអនុវត្តច្បាប់ដែលធ្វើការនៅក្នុងតំបន់ការពារ ក៏ដូចជាដោយមានការចូលរួមក្នុងការថែរក្សាតំបន់ការពារធម្មជាតិពីសំណាក់សហគមន៍មូលដ្ឋាននៅជុំវិញតំបន់ការពារ ព្រមទាំងការអនុវត្តនូវកម្មវិធីអភិវឌ្ឍជីវភាពរបស់សហគមន៍ឲ្យបានប្រសើរឡើង ដែលទាំងនេះជាផ្នែកសំខាន់មួយនៃភាពជាដៃគូយុទ្ធសាស្ត្រសម្រាប់រយៈពេលវែងរបស់ក្រសួងបរិស្ថាន និងអង្គការWWF។

**លោក សេខ ឆៀក** នាយកអង្គការWWFកម្ពុជា បានមានប្រសាសន៍ថា៖ «ខ្ញុំសូមអបអរសាទរចំពោះក្រុមការងារស្រាវជ្រាវ និងក្រុមការងារអនុវត្តច្បាប់ចំពោះគំហើញដ៏អស្ចារ្យនេះ។ ប្រសិនបើគ្មានការប្តេជ្ញាចិត្ត និងការខិតខំដ៏មោះមុត និងដោយទៀងទាត់នៅក្នុងតំបន់ការពារធម្មជាតិនោះទេ យើងទាំងអស់គ្នាក៏មិនទទួលបាននូវលទ្ធផលដ៏ប្រសើរបែបនេះដែរ»។

យើងត្រូវពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការការពារ និងអភិរក្សបន្ថែមទៀត ដោយផ្តល់អាទិភាពលើការស្វែងរកនូវដំណោះស្រាយសមស្រប និងប្រកបដោយភាពច្នៃប្រឌិតសម្រាប់គាំទ្រដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការការពារធនធានសត្វព្រៃ ហើយស្របពេលជាមួយគ្នានោះដែរ បន្តអំពាវនាវឱ្យចាត់នូវវិធានការ និងវិធីសាស្ត្រឲ្យកាន់តែប្រសើរជាងមុនដើម្បីគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងធនធានធម្មជាតិ។

លោកបានបន្ថែមថា៖ «គំហើញនាពេលនេះ បានបង្ហាញថាការស្តារចំនួនសត្វព្រៃនៅតំបន់ព្រៃទេសភាពភាគខាងកើតឲ្យប្រសើរឡើងវិញគឺជាលទ្ធភាពដែលគេអាចធ្វើទៅបាន ដោយបង្កើនកិច្ចសហការរួមគ្នា ដើម្បីរៀបចំឡើងឲ្យមាននូវលក្ខខណ្ឌចាំបាច់នានាដូចជា ការការពារទីជម្រក ការធានាការផ្គត់ផ្គង់ចំណីអាហារ និងទឹកតាមបែបធម្មជាតិ ដែលជាសុទ្ធសឹងជាកត្តាផ្តល់អំណោយផលដល់ការរស់រានរបស់សត្វក្រពើភ្នំ និងប្រភេទសត្វដទៃជាច្រើនទៀតដែលកំពុងរស់នៅក្នុងទីជម្រកធម្មជាតិនៃតំបន់ទេសភាពខ្ពង់រាបភាគខាងកើតនៃកម្ពុជានេះ»។

ក្រសួងបរិស្ថាន និងអង្គការWWF នឹងបន្តតាមដានស្ថានភាពសត្វក្រពើភ្នំនៅតំបន់ស្រែពកតទៅបន្ថែមទៀត និងពង្រឹងវិធានការការពារទីជម្រករបស់សត្វនេះពីការគំរាមកំហែងផ្សេងៗ មានដូចជាការទន្ទ្រានដីដែលធ្វើឲ្យប៉ះពាល់ដល់ទីជម្រក និងសកម្មភាពល្មើសច្បាប់ផ្សេងៗទៀតដោយអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវការចុះល្បាតជាប្រចាំតាមគ្រប់មធ្យោបាយទាំងក្នុងនិងក្រៅតំបន់ការពារធម្មជាតិ។

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន** បានមានប្រសាសន៍ថា៖ «ខ្ញុំសូមអំពាវនាវយ៉ាងទទូចដល់ភាគីពាក់ព័ន្ធទាំងអស់ ឲ្យចាត់វិធានការរួមគ្នាជាបន្ទាន់បន្ថែមទៀតចាំបាច់សម្រាប់ការការពារសត្វក្រពើភ្នំដើម្បីឲ្យសត្វនេះជៀសផុតពីការផុតពូជ និងដាក់ចេញនូវវិធីសាស្ត្រនានាដើម្បីធានាឲ្យសត្វនេះមានចំនួនកើនឡើងវិញសម្រាប់គាំទ្រការរស់រានរបស់វាតទៅអនាគត។ ក្រសួងបរិស្ថានបានត្រៀមខ្លួនរួចជាស្រេចក្នុងការសហការជាមួយអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងបណ្តាដៃគូដទៃទៀត ដើម្បីការពារ និងថែរក្សាធនធានព្រៃឈើ និងមរតកធនធានសត្វព្រៃរបស់កម្ពុជា ដើម្បីផ្តល់ជាប្រយោជន៍សង្គម និងសេដ្ឋកិច្ចសម្រាប់រយៈពេលវែងដល់ប្រជាជនជំនាន់នេះ និងជំនាន់តទៅអនាគត»។

ក្រោមជំនួយឧបត្ថម្ភថវិកាពីទីភ្នាក់ងារជំនួយអាមេរិក (USAID) សហភាពអឺរ៉ុប (EU) រដ្ឋាភិបាលអាល្លឺម៉ង់ (BMZ) រដ្ឋាភិបាលប៊ែលហ្ស៊ិក (DGD) កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (UN Environement) GEF រដ្ឋាភិបាលស៊ុយអ៊ែត (Sida) IKEA Welthungerhilfe (WHH) Humanscale និងបណ្តាញអង្គការ WWF (WWF-អាមេរិក WWF-ប៊ែលហ្ស៊ិក WWF-អាល្លឺម៉ង WWF-ស៊ុយអ៊ែត និង WWF-ស្វីស) ការគ្រប់គ្រងតំបន់ការពារធម្មជាតិនៅក្នុងដែនជម្រកសត្វព្រៃស្រែពក និងភ្នំព្រេច ផ្តោតទៅលើការស្រាវជ្រាវនិងតាមដានជីវៈចម្រុះ ការកសាងសមត្ថភាពសម្រាប់ការអនុវត្តច្បាប់ ការប្រយុទ្ធប្រឆាំងនឹងការបរបាញ់ខុសច្បាប់ ការជួញដូរសត្វព្រៃខុសច្បាប់ ការកាប់ឈើខុសច្បាប់ ការទប់ស្កាត់ការទន្ទ្រានដីព្រៃខុសច្បាប់ ខណៈយកចិត្តទុកដាក់លើការអភិវឌ្ឍរបរចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន និងការអនុវត្តកម្មវិធីផ្សេងៗទៀតដើម្បីលើកទឹកចិត្ត និងកៀរគរការចូលរួមរបស់ប្រជាជនមូលដ្ឋានក្នុងការអភិរក្សធនធានធម្មជាតិ និងអភិវឌ្ឍន៍ជីវភាពប្រកបដោយនិរន្តរភាព។

**ព័ត៌មានបន្ថែមសម្រាប់ការនិពន្ធ៖**

- សូមប្រើតំណរនេះ ដើម្បីទទួលបានរូបភាព និងវីដេអូនៃរបកគំហើញ https://bit.ly/3AjepNP
- រាជរដ្ឋាភិបាលកម្ពុជាបានឈានមុខក្នុងការអភិរក្សសត្វក្រពើភ្នំ ចាប់តាំងពីប្រភេទសត្វនេះត្រូវបានរកឃើញឡើងវិញជាលើកដំបូងក្នុងឆ្នាំ ២០០០។ ក្នុងក្របខ័ណ្ឌនៃកិច្ចសហការរួមគ្នារវាងរាជរដ្ឋាភិបាល និងអង្គការដៃគូនានាត្រូវបានរៀបចំឡើង ក្នុងនោះ កិច្ចសហការរវាងក្រសួងបរិស្ថាននិងអង្គការ WWF បាន និងកំពុងផ្តោតការយកចិត្តទុកដាក់ដោយមិនខ្លាចនឿយហាត់ ក្នុងការអភិរក្សធនធានប្រភេទសត្វដ៏កម្រនជាសកលនេះ។ សមិទ្ធផលសំខាន់ៗមួយចំនួនដែលរាជរដ្ឋាភិបាលកម្ពុជា និងដៃគូសម្រេចបានរួមមានការបង្កើតកម្មវិធីអភិរក្សសត្វក្រពើភ្នំដំបូងនៅក្នុងប្រទេស និងការបង្កើតផែនការថ្នាក់ជាតិសម្រាប់ការស្តារសត្វក្រពើភ្នំឡើងវិញ (២០១២-២០៣១) ព្រមទាំងបានប្រលែងសត្វក្រពើភ្នំជាង ១០០ក្បាលទៅក្នុងព្រៃធម្មជាតិ។
- ក្រសួងបរិស្ថាន និងអង្គការWWF បាន និងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ក្នុងតំបន់ និងដៃគូពាក់ព័ន្ធដើម្បីកសាងវិធានការអភិរក្សចាំបាច់បន្ទាន់សំដៅកាត់បន្ថយការបរបាញ់ខុសច្បាប់ វិបត្តិអន្ទាក់ និងពង្រឹងការអនុវត្តច្បាប់បន្ថែមទៀត។ បច្ចុប្បន្នក្រសួងបរិស្ថាន និងអង្គការ WWF កំពុងសិក្សាអំពីលទ្ធភាពនៃការអនុវត្តកម្មវិធីស្តារសត្វព្រៃ ដែលជាតម្រូវការបន្ទាន់ដើម្បីបង្វែរនិន្នាការថយចុះនៃចំនួនសត្វព្រៃ ខណៈពេលដែលរៀបចំនូវវិធានចំពោះកត្តាដើមចមនៃការជួញដូរសត្វព្រៃ។